# ពាក្យពេចន៍ខ្លះគួរពិចារណា

## សម្រង់ចាកសៀវភៅប្រមូលភាសិតខ្មែរ

### ស្រាវជ្រាវ ចងក្រង និង ចេញផ្សាយដោយៈ **សមាគមសម្តេច ជួន ណាត**

១. បានមកថាតូច រួចទៅថាធំ

២. បុរសទុកដូចជាដី ស្ត្រីទុកដូចជាដី ញាតិមិត្រមូលមីរទុកដូចជាទឹក។

៣. មុនស្តីឱ្យពិនិត្យ ពាក្យណាពិតសឹមចរចា។

៤. បើចង់ចំណេញកុំឱ្យខ្លាចខាត បើចង់ចេះស្ទាត់កុំឱ្យខ្លាចយូរ។

៥. បើអាក្រក់ អាក្រក់ចុះឱ្យតែល្អ បើក្រ ក្រចុះឱ្យតែមាន។

៦. ឮគេឈ្លោះគ្នាកុំចង់ស្តាប់ ក្រែងគេប្រចាប់ធ្វើសាក្សី សក្តិសិទ្ធិប្រាកដស្បថមិនថ្វី អ្នកម្ខាងចាញ់ក្តីគេកើតក្តៅ។

៧. បើចេះតែរៀនឥតបើគិត មិនប្រើគំនិតឱ្យឃើញជ្រៅ មិនរិះឱ្យដឹងរសជាតិជៅ ទោះរៀនចេះទៅក៏នៅខ្សោយ។

៨. បើខឹងកុំរំលោភ បើល្មោភឱ្យល្មមសមនឹងមាឌ កុំមាត់ក្អេងក្អាងក្រែងភ្លាត់ស្នៀត កុំវាតហួសវង់នាំផុងខ្លួន។

៩. បើឡើងដើមឈើឱ្យដល់ចុង បើផុងអន្លង់ឱ្យដល់បាត បើឡើងលើភ្នំឱ្យខ្ពីឃ្លាត ព្យាយាមសង្វាតដល់កំពូល។

១០. បើការស្លាប់រស់កុំប្រាប់ស្រី បើបានជាខ្ចី ខ្ចីប្រាក់ទិញ ការស្ងាត់កំបាំងកុំបញ្ចេញ បើបានជាវេញឱ្យមូលមួយ។

១១. បើច្បាំងត្រូវតែយកឈ្នះចាញ់ បើឆ្លងអារញ្ញឱ្យដល់វាល បើរៀនវិជ្ជាឱ្យផុតពាល ទើបអាចបណ្តាលឱ្យគុណគាប់។

១២. បើលក់ឱ្យលក់មានរព្វក បើភ្លឹកកុំធ្មេចភ្លេចក្នុងក្រៅ តែលក់ក្នុងលោកក្រោកឡើងសៅ អ្នកប្រាជ្ញលោកហៅថាថីនមិទ្ធ (ថីនមិទ្ធ = ដំណើរដេកលក់ ពុំដឹងខ្លួនឬអ្វីដែលកើតឡើងនៅជុំវិញខ្លួន)។

១៣. បើខ្លៅកុំខ្លៅឱ្យដល់ខ្ទាក់ បើស្លាក់កុំស្លាក់ឱ្យដល់ស្មិង បើស្រេកកុំស្រេកដល់ស្រវឹង បើប្រឹងកុំប្រឹងឱ្យដល់ព្រួយ។

១៤. បើខូចកុំខើចឱ្យដល់ខាត បើឆ្លាតកុំឈ្លាសហួសចំណាំ បើកាចកុំកោងបង្កកម្ម បើខាំកុំខាំតាមចិត្តខឹង។

១៥. បើប្រាជ្ញកុំប្រាជ្ញឱ្យដល់ព្រើល បើងងើលកុំងងុលឱ្យដល់ងាប់ បើឆ្លោយកុំឆ្លោយឱ្យដល់ធ្លាប់ បើជាប់កុំជាប់ឥតគេចង។

១៦. បើទោះជាខឹងដូចម្តេចក្តី ត្រូវប្រុងស្មារតីកុំឱ្យឆ្លោយ ខឹងខុសខឹងខាតនាំស្តាយក្រោយ ខឹងនោះនាំឱ្យមានទោសា។

១៧. បើខឹងឱ្យខំអត់ បើខ្សត់ឱ្យខំរក។

១៨. បើគេស្អប់យើង យើងយកស្អប់ទៅតបស្អប់ កាលណានឹងស្ងប់ស្ងាត់បាត់រំខាន ចុះបើយើងយកអភ័យទៅតបវិញថ្កាន តើយើងនឹងបានសុខកាយសប្បាយចិត្តឬទេ ?

១៩. បើធ្វើខុសទោះត្រឹមស្តីអ្វីផ្តេសផ្តាស ត្រូវប្រកាសសុំខមាទោសញាតិមិត្រកុំគិតលាក់
ទើបកំហុសនោះនឹងបាត់ស្ងាត់ជៀងជាក់ ហើយខ្លួនអ្នកនឹងបានល្អតទៅមុខ។

២០. បើអ្នកថានឹងធ្វើការនៅពេលនេះ ហើយអ្នករិះគិតពន្យារទៅគ្រាក្រោយ មុខជាគ្មានពេលនឹងបើកឱកាសឱ្យ
តែបណ្តោយការនោះណាមេម៉ាយហើយ។

២១. បើមិនធ្វើគុណគេក៏ហើយចុះ កុំតែឱ្យទោសកំហុសទៅគេថ្វី បើមិនព្រួយជួយចូកចែវក៏វាហី
កុំតែស្តីរារាំងទៀតឆ្លៀតរករឿង។

២២. បើកក្តោងទាន់មានខ្យល់។

២៣. បំណាច់នឹងចេះឱ្យគេកោត បំណាច់នឹងឆោតឱ្យគេអាណិត។

២៤. បំណាច់នឹងខូចឱ្យបានការ បំណាច់នឹងគេថាឱ្យសើមមាត់។

២៥. បម្រើឪពុកម្តាយ គេនៅឆ្ងាយគេច្រើនគាប់ អ្នកណាបម្រើខ្ជាប់ ធ្លាប់តែខុសពុំដែលត្រូវ។

២៦. ចានក្នុងរាវតែងទង្គិចគ្នា។

២៧. ប៉ះកល់សត្វគោជំបៅខ្នង ក្អែកហើររំលងច្រើនស្ងប់ស្ងែង បោលត្រង់កន្ទុយដោយគិតក្រែង រអែងក្អែកចោះដំបៅខ្លួន។

២៩. នគរមួយស្តេចពីរមិនភិរម្យ វត្តមិនឧត្តមសង្ឃរាជពីរ ព្រះពុទ្ធទ្វេអង្គបង់សាមគ្គី អាទិត្យពីរមុខក្តៅនៅមិនបាន។

៣០. ប្រមាណជម្រៅទឹកឱ្យពិនិត្យ ដកដើមព្រលិតវាស់ស្ទង់វា ប្រមាណត្រកូលអ្នកកាចជា ឱ្យមើលកិរិយាអាការចេញ។

៣១. ប្រយ័ត្នជនណាគេមានល្បិច កែគេចលើកទោសទម្លាក់លើ ខ្លួនគេបានស្អាតល្អប្រសើរ អាក្រក់ធ្លាក់ទើរលើរូបខ្លួន។

៣២. ប្រយ័ត្នពោលពាក្យ ក្រែងបានលំបាកដោយសារសម្ដី គិតរួចសឹមថ្លែងសម្ដែងវាចី កុំឱ្យអប្រិយមន្ទិលដល់ប្រាណ។

៣៣. ប្រយោជន៍ជាតិដូងហើយនិងត្នោត មនុស្សលោកណាឆោតគិតមិនដឹង គេកាប់គេបេះមិនចេះខឹង ប្រឹងតែលូតលាស់រស់បន្ត។

៣៤. ប្រហែសតែងតែបាត់ ប្រុងប្រយ័ត្នតែងគង់នៅ គិតសព្វគ្រប់ដោយផ្សូវ សូវទ្រាំនឿយកុំទ្រាំក្រ។

៣៥. ប្រពន្ធពីរ គោបី ដំរីមួយ នាំឱ្យព្រួយចិត្ត។

៣៦. ប្រមាថព្រៀងលាន តែងមានក្ដីទុក្ខ។

៣៧. ប្រាជ្ញមិនស្មើប្រប ស្លឹកត្រចៀកខ្លប មិនស្មើឡេមឡឺម (អ្នកមានចំណេះពុំស្មើនឹងអ្នកផ្គាប់ផ្គុនអែបអប អ្នកបម្រើនឿយហត់ខ្លបខ្លាចជានិច្ចពុំស្មើនឹងអ្នកមកធ្វើឡេមឡឺមម្ដងៗ)។

៣៨. ប្រាជ្ញមែនហើយនៅឡើយមិនទាន់ផុតពាល ចេះវាល់វាលនៅតែលង់លូង់ខ្លះដែរ កុំអាងប្រាជ្ញអាងចំណេះចេះពូកែ កុំឱ្យគេសើចថាចេះរបេះក្បាច់។

៣៩. ប្រើបាវមើលចិត្តវា កុំបំពារផតប្រណី សត្វបម្រើនោះសោតខ្មី ត្រូវមេត្រីឱ្យស្មោទឹក។

៤០. បើស្រែចេះស្រែ ករៀនកែប្រែចាំស្ទាត់ចំណេះ ហាត់ចិត្តស្គាល់ចិត្ត ហាត់សេះស្គាល់សេះ ដំដែកស្គាល់ច្រែះ ចង់ចេះខំដាំ។

៤១. ផឹកស្រាក្លាសម្ដី។

៤២. ផោមក្នុងទឹកម្ដេចគង់ស្អុយ។

៤៣. ផ្កាឧប្បលក្រអូបឯង គ្មានគេចាត់ចែងដាក់ទឹកអប់ កុលបុត្រចេះដឹងសព្វ គ្មានចាំបាច់គេដាស់តឿន។

៤៤. ផ្គាប់គ្រូមិនសូវមានគ្រោះខ្លួន បើផ្គាប់ឱ្យមួនកុំសង្ស័យ ខុសពីរបើដងលោកអភ័យ បើមានចំណីទុកឱ្យស៊ី។

៤៥. ផ្ទុករទេះតាមចំណុះ។

៤៦. ផ្លូវវៀចកុំបោះបង់ ផ្លូវណាត្រង់កុំដើរហោង ដើរដោយផ្លូវគន្លង តម្រាយបុរាណាចារ្យ។

៤៧. ផ្លូវវៀចកុំបោះបង់ ផ្លូវព្រៃត្រង់កុំយាត្រា ឈានឈរពិចារណា ឆ្ការឱ្យស្អាតសឹមដើរទៅ។

៤៨. ផ្លែត្រឡាចគង់មានបណ្តូល មនុស្សមួយទាំងមូលឯណាគ្មានចិត្ត។

៤៩. អ្នកធ្វេសស្មារតីស្លាប់គំនិត ទោះបីមានជីវិតរស់នៅឡើយ។

៥០. ពពកជាលម្អនៃនភាល័យ បុប្ផាប្រិមប្រិយជាលម្អនៃរុក្ខា រលកជាលម្អនៃសាគរា វិជ្ជាប្រាជ្ញាជាលម្អនៃមនុស្ស។

៥១. ពស់កាចអាចទ្រុស្តទោះវាខាំ ពេទ្យកែដោយថ្នាំអាចស្ងប់បាន មនុស្សពាលកាចលើសពស់សាមាន្យ ពុំមានអ្វីកែបានស្ងប់ឡើយ។

៥២. ពាក្យខុសកុំស្តាប់ ក្តីគាប់ឱ្យរិះឲ្យាន។

៥៣. ពាក្យក្រកុំអាលប្រាប់ ពាក្យឥតស័ព្ទកុំអាលថ្លែង។

៥៤. ពាក្យចាស់អង្វរ ថាបើខ្លាចក្រ បាខំធ្វើស្រែ កាប់កាយធរណី ដាំយកផ្កាផ្លែ លក់ដូរជួញប្រែ មាសប្រាក់រត់ហៅ។

៥៥. ឯល្បែងនានា គឺជាពូជចោរ នៃទុក្ខសោកសៅ មិនដែលអ្នកលេង ធ្វើជាជង្ហៅ បានឈ្នះច្រើនទៅ ស្លៀកពាងក្រឡ។

៥៥. ពាក្យស្លែងកុំស្តាប់ ពាក្យគាប់ឱ្យយក។

៥៦. ពាក្យលើកបញ្ជោរឬបង្អាប់ នាំឱ្យអ្នកស្តាប់ភ័ន្តស្មារតី ដោរចើចតាមធម៌ជាលោកិយ នេះជនប្រុសស្រីគួរប្រយ័ត្ន។

៥៧. ពាក្យបុរាណខ្មែរ អ្នកប្រាជ្ញលោកកែ ឱ្យគិតប្រយោល ចោលសាច់យកឆ្អឹង ប្រឹងតែខំថ្កោល ទោសពិតឥតពោល អំពើពុតពាល។

៥៨. ពាក្យចាស់បុរាណលោកប្រដូច កុំបោះសន្ទូចរំលងភ្នំ គិតការទាំងពួងកុំចោលចាស់ទុំ កុំរំលងអ្នកធំទៅផ្គាប់អ្នកតូច។

៥៩. ពាលខ្លៅចូលនៅផងបណ្ឌិត គ្រាអស់ជីវិតលង់អនេក មិនដឹងរសធម៌អាថ៌ជាឯក ដូចវែកមិនដឹងរសសម្ល។

៦០. ពាលឯណាដឹងខ្លួនថាពាលពិត ពាលនោះហៅបណ្ឌិតដោយអនុយោគ (អនុយោគ = ពាក្យសួរ, ប្រស្នា) ពាលណាកាន់ខ្លួនថាប្រាជ្ញព្រោក ពាលនោះឯងលោកហៅថាពាលពិត។

៦១. ពុទ្ធរូបល្អក៏ដោយសារស្នាដៃជាង រចនារូបរាងព្រាងសិតឥតធ្លង ការល្អអាក្រក់គឺតាមគន្លង ដោយហេតុដើមទងអំពីអ្នកធ្វើ។

៦២. ពូជសិស្សគ្រូបី ពូជស្រីប្តីលែង ពូជគោជ្រលែង ពូជឆ្កែបង់ម្ចាស់ ... ពូជពួកបែបនេះ គួរឱ្យប្រយ័ត្ន។

៦៣. ពូជខ្លាមិនដែលចង់ចោលព្រៃ មច្ឆាជលស័យមិនចោលទឹក ពូជចោរមិនចោលចោរកម្មិក ( កម្មិក = រួមការងារ, រួមសម្ព័ន្ធ ) ជនពាលប្រមឹកមិនចោលចិត្តខូច។

៦៤. ពួកមនុស្សមុយៗបែបមឹសៗ អង្គុយក្លឹះៗទន់ពត្លៀច សម្ដីល្អកល្អឺនល្អល្មៀចៗ តែងមានចិត្តកៀចកលឧបាយ។

៦៥. ជនណាដាក់ចិត្តរៀនសើៗ ដល់ដប់មិនស្មើប្រសប់មួយ អ្នកចេះគួររកប្រសប់ជួយ លើកស្ទួយចំណេះឱ្យគ្រាន់បើ។

៦៦. មនុស្សណាគ្មានវិជ្ជាមិនចេះច្បាប់ មនុស្សនោះដូចស្លាប់ឥតប្រយោជន៍ ដូចភ្នែកដែលខ្វាក់គួរអាសោចន៍ នាំឱ្យហិចហោចដល់អាត្មា។

៦៧. អ្នកដែលនៅក្រមិនទាន់មាន តែងនឹកស្រេកឃ្លានចង់បានច្រើន រីអ្នកដែលមានក៏ក្រវើន ( ក្រវើន = ឧស្សាហ៍, ខិតខំ ) នៅចង់បានកើនលើសច្រើនអើយ តណ្ហាមនុស្សលោកមិនចប់ឡើយ ចំណង់នេះហើយចំណងទុក្ខ។

៦៨. រីអ្នកទាបតូចល្ងិតល្ងង់ខ្លៅ ទៅកាងក្អេងក្អាងគិតវាទអាទិ៍ ចង់បានយសសក្ដិធំហួសមាឌ នឹងខាតកម្លាំងនាំរំខាន។

៦៩. អ្នកខ្ជិលមិនខំរៀន ឱកាសត្រូវធ្យាន ( ធ្យាន = ឈានទៅរកចំណេះដឹង )មិនខំសង្វាត ដូចសត្វពានរមិនស្គាល់មណីជាតិ ពេជ្រល្អដល់ខ្នាតបែរបោះជាល្បែង។

៧០. បើខ្លួនឯងចាស់ទៅឆ្លោយគំនិត ប្រព្រឹត្តិការល្បែងទាស់ចំណាប់ ជាមួយក្មេងៗរមែងអាប់យសស័ក្ដិខ្ពស់ផ្កាប់ក្រឡាប់ថោក។

៧១. ប្រលែងនឹងឆ្កែ ឆ្កែលិទ្ធមាត់។

៧២. យសសក្ដិទ្រព្យផងនិងកេរ្តិ៍ឈ្មោះ តែងប្រែប្រួលខុសដូចសុរិយា មិនដែលនៅទៀងទិសបូព៌ានេះរឿងធម្មតានៃលោកិយ។

៧៣. ព្រៃគ្មានសត្វជិត នគរឥតបណ្ឌិត ស្រុកឥតសាសនា ត្រីហាឥតបុត្រ មេឃឥតសុរិយា ទាំងអស់នេះណាអសារឥតន័យ។

៧៤. មនុស្សលោភមានពីណាការខ្មាសអៀន មនុស្សខ្ជិលរៀនមានពីណាវិជ្ជាជាក់
មនុស្សក្រោធច្រើនមានពីណាអស់មិត្តភក្តិ ទានមិនដាក់មានពីណាចិត្តសប្បុរស។

៧៥. មនុស្សយកសម្ដី ដំរីយកភ្លុក។

៧៦. មនុស្សខឹងកុំឱ្យលាងចាន មនុស្សឃ្លានកុំឱ្យដាំបាយ។

 ដកស្រង់និងកែសម្រួលដោយ ប៊ុនចាន់ សុក្រសិរី

៧៧. មនុស្សទាបតែងចង់ខ្ពស់ ក្រទុរយសអួតធនធាន អ្នកខ្លាចវែងធ្វើជាហ៊ាន អ្នកប្រាជ្ញគ្មានរមែងធ្វើចេះ។

៧៨. មនុស្សឥតគំនិត មានទ្រព្យច្រើនពិត ហៅក្រពេកពន់ ចេះមិនប្រតិបត្តិ ហៅល្ងង់លើសលន់ មានកិរិយាគុណ ហៅមានប្រាកដ។

៧៩. មនុស្សលើផែនដី បុរាណស្រដីតាមន័យភាសិត ថ្លៃថោកយ៉ាងណាកិច្ចការកម្រិត ទៅតាមគំនិត ជាតិមនុស្សថោកថ្លៃ។

៨០. មនុស្សនៅក្នុងលោក មានច្រើនគរគោក ត្រូវប្រាស្រ័យគ្នា អ្នកខ្លះធ្វើស្រែ ខ្លះធ្វើចម្ការ ជាងសង់គ្រឹហា មុខការរៀងខ្លួន។

៨១. មនុស្សហើយនឹងមនុស្ស តែងមានត្រូវខុសទាស់ទែងខ្វែងគ្នា។

៨២. មនុស្សសត្វក្នុងលោក តែងជួបទុក្ខសោកព្យាធិមរណា ធំតូចខ្ពស់ទាបស្ដេចរាស្ត្រប្រជា ទោះនៅទីណា សឹងមរណ៍សូន្យបង់។

៨៣. មនុស្សរើសចំណី ឆ្កោប្រាមិនធីរើសឆ្មើងបែរបៀង រកជ្រូកមាន់ទាសម្រាប់ជប់លៀង ដល់ឃ្លានមិនទៀង លូកពាងប្រហុក។

៨៤. មនុស្សខឹងច្រើន ច្រើនខុស មនុស្សឈ្លោះច្រើន ច្រើនប្រមាថ ការល្អច្រើនត្រូវខ្វាត បើចង់ស្អាតកុំខ្លាចយូរ។

៨៥. មនុស្សជាគេថាឆោត មនុស្សប្រាជ្ញគេថាព្រើល។

៨៦. មនុស្សប្រាសចាកគុណ ទុកជាមានបុណ្យត្រកូលធំខ្ពស់ ក៏គ្មានប្រយោជន៍ដល់អ្នកសេពសម គ្រាន់តែខ្ពស់ធំៗ មិនប្រសើរ។

៨៧. មនុស្សល្ងង់តែងខ្លួន បិទបាំងបំពួនដោយសំពត់ស្បៃ មើលពីចម្ងាយសមល្អប្រពៃ ដល់ហាមាត់ស្ដីគេដឹងថាខ្លៅ។

៨៨. មនុស្សកាចប្រាកដ លាក់ពុតមិនមាត់ ធ្វើឫកសុភាព ឯមនុស្សព្រហើន ឫកមិនរាបទាប ពាក្យឥតសុភាព នាំឱ្យគេស្អប់។

៨៩. មានវិជ្ជាជាពន្លឺភ្លឺសាយសុស នាំឱ្យមើលឃើញកំហុសរបស់អ្នកខ្លៅ បើឃើញហើយត្រូវបង្រៀនប្រៀនប្រដៅ ទើបឈ្មោះហៅថាអ្នកចេះប្រាកដមែន។

៩០. មានទ្រព្យមិនស្មើមានវិជ្ជា មានរោគាមិនស្មើពាលរំខាន ស្រឡាញ់អ្វីមិនស្មើស្រឡាញ់ប្រាណ កម្លាំងអ្វីមិនស្មើកម្លាំងកម្ម។

៩១. អ្នកវិជ្ជាម័ទ (វិជ្ជាម័ទ = ស្រវឹងនឹងវិជ្ជា, ក្អេងក្អាងព្រោះគិតថាខ្លួនមានវិជ្ជា) ច្រើនតែវិបត្តិ ដោយក្តីមើលងាយ អ្នកចេះផងគ្នា ថាជនសម្មាយ ព្រោះក្តីមាក់ងាយ គេស្អប់ជុំខ្លួន ។

៩២. មានផ្លូវឥតមនុស្សដើរ តាមដំណើរពីព្រេងនាយ អ្នកស្រែក៏អត់បាយ អ្នកព្រៃឆ្ងាយគ្មានអុសដុត។

៩៣. មានបុណ្យពុំស្មើមានសម្បត្តិ មានធនធានក្តាត់ពុំស្មើមានកុសល មានបរិវារពោរពាសពុំស្មើមានបុត្រនិមល មនុស្សផងរចល់ពុំស្មើមានព្រះពុទ្ធមួយ។

៩៤. មាសប្រាក់ទាំងឡាយ ទ្រព្យផងសម្មាយ ទោះច្រើនយ៉ាងណា បើឥតសុខកាយ ឥតសប្បាយចិន្តា ចាស់លោកពោលថា ទ្រព្យពុំប្រសើរ។

៩៥. មិត្រមួយសោតណា ទៅមកកាន់គ្នា បង្កើតឱ្យសុខ មិត្រនោះប្រសើរ អ្នករក្សាទុក រាប់អានទៅមុខ ទុកជាទ្រព្យា។

៩៦. មិត្រមួយឱ្យហីន ទៅមកខ្វាន់ៗ ដក់ថ្នាំស៊ីស្លា ចុះឡើងឥតអាក់ បង្ហិនទ្រព្យា កូនអើយអ្នករៀរ កុំធ្វេសអាត្មា។

៩៧. មិត្រល្អឱ្យសុខ បាបមិត្រឱ្យទុក្ខ គ្រប់ទិនទិវា មិត្រល្អក្រមាន ខ្ពស់ទាបយ៉ាងណា តែងយកអាសា ដាស់តឿនខុសត្រូវ។

៩៨. មិនត្រូវរង់ចាំព្រេងវាសនា មិនត្រូវធ្វើការខុសលំអាន មិនត្រូវខ្ជិលរៀនទូន្មានប្រាណ មិនត្រូវឱ្យទានគ្មានពិចារណ៍។

៩៩. មិនទាន់ចាស់កុំអាលបេះមកបន្ទុំ ដាក់ជាពុំមានរសផ្អែមល្ហែមឡើយណា មិនទាន់ចេះកុំអាលអួតអាងអាត្មា នឹងនាំខូចការអេសារកេរ្តិ៍។

១០០. មួយសេនសន្សំ ចូលចង់ប្រជុំផ្សែផ្សំគ្នីគ្នា យូរទៅគង់បានច្រើនណាស់ណា តិចៗផ្ទួនគ្នាក្លាយជាសេដ្ឋី។